# ២០.ប្រាជ្ញាអណ្តើក

អណ្តើកជាសត្វរស់នៅក្នុងទឹកបឹងក៏បាន លើគោកក៏បាន ។ ហេតុដើមនោះ មានរឿងព្រេងមួយនិទានថា ៖ ក្នុងគ្រាយូរយារអង្វែងហើយ ពេលនោះមានទឹកជំនន់ធំណាស់ ។ សត្វខ្លា ដំរី រាជសីហ៍ រមាំង រមាស ក្តាន់ជាដើម អំពាវនាវបបួលគ្នាទៅពួននៅព្រៃហេមពាន្ត នៅសល់តែអណ្តើកសកលមួយ មិន

ព្រមទៅណានឹងគេសោះ លុះទឹកជំនន់មកដល់ គាត់ក៏ហែលលេងជាមួយនឹងពពួកមច្ឆជាតិ ស៊ីមើមឈើ ឫសឈើ ។ កំពុងតែសប្បាយស្រាប់តែទឹកស្រកទៅវិញ អណ្តើកភ្លេចខ្លួន ក៏ជាប់ខ្លួននៅនឹង

តង្កៀបឈើ តែលតោលពុំដឹងជាទៅខាងណា នឹកថាអាត្មាអញមុខជាស្លាប់ហើយ ព្រោះដៃជើងខ្លី ៗ ។ លុះទឹកស្រកផុតពីគល់ឈើទៅវិញ មានល្បះស្មៅខ្ចីដុះនៅគល់ឈើជាច្រើន ពេលនោះមានដំរី

មួយ ដើរមកបរិភោគស្មៅខ្ចី អណ្តើកឃើញដំរីហើយនឹកថា "អើបានការហើយអញបោកដំរីនេះម្តង ឲ្យវាដឹងដៃ" អណ្តើកក៏បន្លឺវាចាថា ៖ នរណាមកធ្វើអ្វីក្រោមដើមឈើនេះ ? ដំរីឆ្លើយថា ខ្ញុំជាដំរី។

អណ្តើកថា "យើបងដំរី បងឯងមិនទាន់ដឹងខ្លួនទេឬ ខ្លួនខ្ញុំនេះជាអគ្គរាជទូត ព្រះបាទពារាណសី ឈ្មោះថាអ្នកហ្លួងចូលចិត្តមាណព ព្រះករុណា បានប្រើអញឲ្យចាំរកឯងក្នុងទីនេះ ឥឡូវប្រទះគ្នា

ហើយ ចាំអញនិយាយប្រាប់បងឯង ពូជពង្សបងឯងនេះ ពីដើមមកនៅបម្រើ ជាបរិពារព្រះរាជា ហើយស្រាប់តែលួចរត់បាត់ យកទាំងផ្លិតចាមររបស់លោក មកជាមួយផង" ។

- ដំរីឮហើយក៏ភ័យញ័ររន្ធត់ឆ្លើយថា "ឱបងអ្នកហ្លួងអើយ ខ្ញុំពុំដឹងទេ ខ្ញុំឃើញតែរបៀបយ៉ាងហ្នឹង នេះជាកន្ទុយរបស់ខ្ញុំទេតើ" ។
- អណ្តើកនិយាយកាត់ថា ៖ អើហ្នឹងហើយ អញមានថាឯងលួចអី តែដូនតាឯងជាអ្នកលួច ប៉ុន្តែរបស់នៅលើរូបអ្នក បើចង់រួចខ្លួនត្រូវស្វែងរកសត្វជើងមួយមកឲ្យអញ អញយកទៅថ្វាយព្រះរាជា

ជួយសុំអង្វរក្រែងបានរួចខ្លួន ។ ដំរីឮដូច្នេះ ក៏ម្នីម្នាដើរទៅរកសត្វជើងមួយ ទាំងយំស្រែក ។ ខ្លាមួយឃើញដំរីដើរយំស្រែក ហើយសួរថា "នែបងដំរី បងឯងមានទុក្ខពីរឿងអ្វី ក៏ដើរយំស្រែកដូច្នេះ "។

ដំរីសោសព្ទ ប្រាប់ខ្លាសព្វគ្រប់ ខ្លាថា "យីបងដំរីម្តេចក៏ទៅចាញ់បោកអាសត្វអណ្តើកចង្រៃ មកយើងទៅពីរនាក់ទៅមើលវាមើល៍" ។ ខ្លានិងដំរីបបួលគ្នាដើរត្រឡប់មកវិញ អណ្តើកក្រឡេកឃើញពី

ចម្ងាយ នឹកថា "អៃយ៉ា បានខ្លាមួយមកទៀតផង មិនអីទេចាំមកជិតអញ នឹងកំហែងអាខ្លានេះម្តង " ។ លុះខ្លានិងដំរីដើរមកដល់ជិត អណ្តើកតាំងស្រែកថា អើអញឮសូរមាត់ដូចជាអាជាត្បេះឬ ?

ខ្លាឆ្លើយថា "ខ្ញុំហ្នឹងហើយ" អណ្តើកនិយាយថា "នែ ! អាជាត្បេះឯងមានរឿងធំណាស់ ម្តេចឯងបានជាភ្លួយក្រឡាខ្លារបស់ព្រះរាជាមក" ។

ខ្លាថា "ទេលោក ! ខ្ញុំឃើញអីចឹងតាំងពីកើតមក " ។
អណ្តើកប្រាប់ថា " ហ្នឹងហើយអញមិនថាឯងលួចទេ ប៉ុន្តែភស្តុតាងនៅលើឯងស្រាប់ ហើយបើចង់រួចខ្លួនទៅជួយរកអាសត្វជើងមួយ ជាមួយនឹងដំរីទៅ អាភ្លើ" ។
ខ្លានិងដំរីដើរបណ្តើរ យំបណ្តើរទៅរកសត្វជើងមួយ ទៅជួបនឹងស្វា ស្វាឆ្ងល់ណាស់ ឃើញខ្លានិងដំរីមានអាការៈដូច្នោះ សួរដឹងដើមទងហើយ ស្វាលាន់មាត់ថា " យីបងឯងទាំងពីរ ច្បាស់ជាចាញ់

បោកអាសត្វអណ្តើកហើយ ដូច្នេះត្រូវត្រឡប់ទៅវិញជាមួយអញ អញនឹងសាកសួរវាមើល៍ " ។ សត្វទាំងបីក៏នាំគ្នាត្រឡប់មកវិញ អណ្តើកឃើញស្វា នឹកថា អញបោកអាស្វានេះទៀត ហើយក៏ស្រែក

ថា " យើបងអាចារ្យស្វាទេតើ ខ្ញុំរកតែមុខ កន្ទុយបងឯងជាអ្វី នៃខ្ញុំប្រាប់ឲ្យច្បាស់ទៅ គឺជាដងលំពែងព្រះរាជា ទៅកុំនិយាយអ្វី ទៅរកសត្វជើងមួយមកឲ្យឆាប់ " ។

ខ្លា ដំរី និង ស្វា ទាល់ប្រាជ្ញ ក៏នាំគ្នាដើរយំបណ្តើរ ទៅរកសត្វជើងមួយ ពុំដឹងសត្វនោះនៅឯណា ទៅជួបនឹងក្ងោក ក្ងោកសួរដឹងរឿងហេតុក៏និយាយប្រាប់ថា "បងទាំង ៣ ចាញ់ប្រាជ្ញវាហើយ មក

ទៅជាមួយខ្ញុំ ខ្ញុំនឹងសាកសួរវាឲ្យដឹងឫសគល់" ។

ខ្លា- ដំរី-ស្វា -ក្ងោក ត្រឡប់មកវិញមិនទាន់ទាំងសួរថាដូចម្តេចផង អណ្តើកក៏ស្រែកថា " យើ បងអវៈសិទ្ធរតើមករកអ្វី យើ ! អានេះខូចណាស់ ហ៊ានលួចផ្លិតកន្ទុយក្ងោកព្រះរាជាមកជាមួយ

ផង" ។

- ក្ងោកភ័យខ្លួន " នឹកថាអែយ៉ា លេងឯងទៀតហើយតើ "។
- អណ្តើកកំហែងថា: ទៅ ! មិនរួចខ្លួនទេ ទៅរកសត្វជើងមួយមកឲ្យអញ ។
ខ្លា ដំរី ស្វានិងក្ងោក ដើរទៅរកសត្វជើងមួយទៀត ពុំដឹងជានៅឯណាទេ អាសត្វជើងមួយនោះ ។ ស្រាប់តែទៅជួបនឹងសត្វទន្សាយ ទន្សាយសួរដឹងរឿងក៏និយាយថា បងឯងទាំងអស់គ្នាមកទៅជា

មួយអញ ចាំអញដោះស្រាយ ។ លុះសត្វទាំង ៥ បណ្តើរគ្នាមកដល់ អណ្តើកឃើញទន្សាយ នឹកថា "អែយ៉ា អាទន្សាយមកជាមួយផងតើ អានេះមានប្រាជ្ញាណាស់ បើអីចឹងត្រូវអញនិយាយទាក់ទង

គន្លងឲ្យមាំទាំទើបឈ្នះវា " ហើយស្រែកសួរពីចម្ងាយទៅថា ៖

-យី អញមើលទៅឃើញដូចជាបងសុភាទន្សាយ យីបងសុភា ! ពូជពង្សបងឯងសុទ្ធតែធ្វើនាម៉ឺនកាត់ក្តីទាំងអស់ ពុំគួរបងឯងមានចិត្តពាលា លួចយកប៉ែននំបញ្ចុកព្រះរាជាដូច្នេះសោះទេ ! ហ្នឹង

ហើយគេហៅថា ចិត្តជាទេវទត្ត មាត់ជាទេវតា !

- ទន្សាយនឹកថា " យីអញថាមកជួយគេ ឥឡូវទៅជាជាប់ពិរុទ្ធខ្លួនឯងទៀត" រួចឆ្លើយថា ៖
- នែបងអណ្តើក ខ្ញុំកើតឡើង ឃើញតែគូទខ្ញុំមានរន្ធច្រើនអីចឹងស្រាប់ ពុំមែនខ្ញុំលួចទេ !
អណ្តើកបានដៃហើយ ក៏ជេរថា " យីអាចង្រៃអស់នេះ ល្ងង់ដូច្នេះតើ បានជារកសត្វជើងមួយមិនបានសោះ ចាំអញប្រាប់ឲ្យច្បាស់ទៅ សត្វជើងមួយគឺផ្សិតនេះឯង ប៉ុន្តែអញមិនប្រាប់ត្រង់ អញចង់ដឹង

ប្រាជ្ញអាឯងទាំងអស់គ្នាមើល៍ តើប្រាជ្ញដូចអញ ឬ មិនដូច ! ”

សត្វទាំង ៥ គឺខ្លា ដំរី ស្វា ក្ងោក និងទន្សាយ នាំគ្នាទៅដកផ្សិតបានយ៉ាងច្រើន យកមកប្រគល់ឲ្យអណ្តើក ។ អណ្តើកក៏អនុញ្ញាតឲ្យស្វាឡើងដើមឈើ ទៅលើកខ្លួនដាក់ចុះពីតង្កៀបឈើ រួចប្រើឲ្យ

ធ្វើកូនខ្ទមលើខ្នងដំរីនិងបិទបាំងជុំវិញ ហើយយកផ្សិតទៅដាក់ក្នុងខ្ទមនោះ ខ្លួនឯងក៏ពួនស៊ីផ្សិតក្នុងខ្ទម យ៉ាងឆ្ងាញ់ពិសា ។ អណ្តើកបញ្ជាឲ្យដំរីដើរទៅរក នគរពារាណសី ឯខ្លា ស្វា ក្ងោក និងទន្សាយ

ក៏ចេះតែដើរទៅដែរ ដើម្បីដោះសាខ្លួនឲ្យរួចពីពិរុទ្ធ លុះបានទៅដល់ស្រះមួយយ៉ាងធំ មានផ្កាឈូកច្រើនទើ អណ្តើកធ្វើជាឧបាយកលបោកសត្វទាំងនេះទៀត ថា

- នែបងដំរីឈប់សិន ! ទាំងអស់គ្នាស្តាប់អញ អញជានាម៉ឺនក្នុងវាំង បើអញចូលវាំងម្តង ៗ ពួកស្រីស្នំ ចេះតែនាំគ្នាសុំផ្កាឈូកពីអញបើដូច្នេះ ត្រូវបងស្វាដាក់អញ ចុះពីដំរី ។
ស្វាឮហើយក៏ស្ទុះទៅដាក់អណ្តើកពីលើខ្នងដំរី រួចហើយអណ្តើកវារចូលទៅពួនសម្ងំក្នុងស្រះនោះបាត់ទៅ ។ ឯដំរី ខ្លា ស្វា ក្ងោក និងទន្សាយ ចាំយូរពេកមិនឃើញអណ្តើកចេញមកវិញសោះ ទើប

ដឹងខ្លួនថាចាញ់បោកអណ្តើកហើយ ទើបនាំគ្នាជៀសចេញពីទីនោះទៅ ។

នេះហើយចាស់ទុំច្រើននិយាយថា " ចេះលាក់ពុតមើលតែអណ្តើក " ព្រោះអណ្តើកវាលាក់ខ្លួននៅក្នុងស្នូក ជានិច្ច តែបើផុតពីគ្រោះភ័យ អាចចេញក្បាល ដៃ ជើង មកក្រៅ បានការតែម្តង ។